

# លោក វ៉ា-គឹមហុង និង យុទ្ធសាស្ត្រថ្មី

លោក វ៉ា-គឹម-ហុង គាត់និយាយថា ផែនទីដែល អ.ស.ប. គ្រោងនឹងប្រគល់ឲខ្មែរ ជាផែនទី ដែលខ្មែរធ្លាប់ប្រើប្រាស់ ក្នុងទស្សវត្សរ៍ ទី៦០ តវ៉ាប្រឆាំងនឹង សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក នៅតាមព្រំដែន រវាង កម្ពុជា នឹងយៀកណាម គឺមិនមែនផែនទី ទីខ្សែព្រំដែន ដែលអាចទុកជាអធិប្បតេយ្យភាពកម្ពុជា បាននោះទេ។

សំដី លោក វ៉ា-គឹមហុង នេះ បញ្ជាក់ឲឃើញថា បុគ្គលនេះ មិនស្គាល់ថាអ្វីជាផែនទីជាតិនោះផង។ មនុស្សបែបនេះហើយ ដែលយួន គេយកមកធ្វើជាដៃគូរ សំរាប់គូសខ្សែព្រំដែនជាមួយគេ ព្រោះគេដឹងថា គាត់គ្មាន សមត្ថភាពអ្វីបន្តិច សំរាប់ ជជែក បញ្ហាព្រំដែនជាមួយគេបាននោះឡើយ។

លោក វ៉ា-គឹមហុង អាចទុក លោក ហ៊ុន-សែន ជាកូនក្មេងបាន ក្នុងការលើក ទន្សឹករណ៍បែបនេះ មកប្រើ តែគាត់មិនអាច ទុកខ្មែរដ៏ទៃជាកូនក្មេងបាននោះឡើយ ព្រោះសំដីគាត់ វាគ្មានសមហេតុផល ទាល់តែសោះ កាលដែលគេយកផែនទី មួយ មកតវ៉ាប្រឆាំងនឹង ការរំលោភ អាធិបតេយ្យភាពទឹកដីជាតិ គឺច្បាស់គេទុកផែនទីនោះ ជាផែនទីជាតិបញ្ជាក់ច្បាស់លាស់ពី ខ្សែព្រំដែន នោះឯងហើយ។ តែយើងមិនឆ្ងល់ទេ តាំងពីយូរយាមកហើយ លោក វ៉ា-គឹមហុង តែងតែនិយាយថា ស្រុកខ្មែរគ្មានព្រំដែនពិតប្រាកដទេ សំដីនេះត្រូវបាន សព សម្តេច សីហនុ មានប្រតិកម្មថា បើនរណាម្នាក់និយាយថា ស្រុកខ្លួនគ្មានព្រំដែនពិតប្រាកដទេ គឺ ជាសំដីសម្លាប់ជាតិតែម្តង។

ហេតុដូច្នេះហើយ បានជា វ៉ា-គឹមហុង ហ៊ានថ្លែងជាសាធារណ: ថាផែនទី ដែលគាត់យកមកប្រើប្រាស់ គឺជាផែនទី ដែលយួនគេប្រគល់ឲគាត់។ យើងយល់ថា ប្រហែលជា វ៉ា-គឹមហុង មានជំនឿថា យៀកណាម គេមានព្រំដែនគេ ច្បាស់លាស់ បានជាគាត់, ក្នុងឋានៈគាត់ជាអ្នកទទួលខុសត្រូវបញ្ហាព្រំដែន, ឥតដែលសួរជាសំណួរថា ផែនទី ដែលយួនប្រគល់ឲគាត់ ជាផែនទីក្លែងក្លាយ ឬ ជា ផែនទីជាតិខ្មែរពិតប្រាកដ ដើម្បីទុកជាមូលដ្ឋាន សំរាប់យកមក ធ្វើការប្រៀបធៀប ជាមួយផែនទី យៀកណាម។

ក្នុង ការជជែកគ្នា អំពីបញ្ហាព្រំដែន រវាង ខ្មែរ-យៀកណាម គឺ មានតែផែនទីមួយគត់ជារបស់យៀកណាម នាំគ្នាយកមក ធ្វើជាមូលដ្ឋាន សិក្សា ហើយយួន គេចុចយកដីខ្មែរ ត្រង់ៗតែម្តង បើខ្មែរចង់តវ៉ា ត្រូវខ្មែរយកឯកសារមកសំអាង។ តែ លោក វ៉ា-គឹមហុង គាត់មានឯកសារ ឯណា យកមកសំអាងបាន ព្រោះផែនទី របស់គាត់ ជាផែនទី របស់យួនរួច

ឧប សៅ សង្ហា
២៦ កក្កដា ២០១៥

ទៅហើយ។ នេះហើយ ជារឿងពិត ដែល លោក សុខ-អាន គាត់និយាយថា មានតែក្រុមគាត់ទេ ហ៊ានធ្វើបញ្ហា ព្រំដែនជាមួយយៀកណាម។

លោក វ៉ា-គឹមហុង គាត់ និយាយដោះសារឲតែបានឈ្នះ ហើយ ទន្ទឹករណ៍ ថ្មីរបស់គាត់នេះ យើងក៏ធ្លាប់បានឮ លោកផៃ-សីផាន អ្នកនាំពាក្យ នៃរដ្ឋាភិបាល លើកមកនិយាយដែរ ដូច្នេះ ប្រជាពលរដ្ឋខ្មែរ ត្រូវរង់ចាំមើលថា លោក ហ៊ុន-សែន គាត់នឹងមិនទទួលស្គាល់ផែនទី ដែល អ.ស.ប. គ្រោងនឹងប្រគល់ឲកម្ពុជា នោះឡើយ។ ដូច្នេះ ហ៊ុន-សែន គាត់គ្មានសន្ដានចិត្តល្អ ដើម្បី ការពារបូរណភាពទឹកដីខ្មែរ នោះទេ ហើយគាត់យក ការបដិសេធនេះ ជា យុទ្ធសាស្ត្រ សំរាប់ ការពារ នយោបាយ របបគាត់ ស្ដីពីបញ្ហាព្រំដែន ខ្មែរ-យៀកណាម។ ដូច្នេះអ្វីដែល លោក វ៉ា-គឹមហុង ចង់បាន គឺជាចំណង់ របស់ ហ៊ុន-សែន តែប៉ុណ្ណោះ។

រីឯ សម-រង្ស៊ី វិញ គាត់ រត់ចោលប្រជាពលរដ្ឋបាត់ទៅហើយ ហើយរឿងយក ផែនទី ដែលគាត់ទិញបាន ពីទីក្រុងបារីស ទៅ ប្រៀបធៀបនឹងផែនទី វ៉ា-គឹមហុង ដែលជាផែនទីយួន គាត់បានបោះបង់គំនិតនេះចោលបាត់ទៅហើយ ព្រោះគាត់ខ្លាច ហ៊ុន-សែន ចាប់គាត់ដាក់គុកព្រៃស។ ដូច្នេះ បើពលរដ្ឋខ្មែរ គ្មានសកម្មភាព ឯកឯង ដើម្បី ការពារបូរណភាពទឹកដី គឺ បញ្ហា ព្រំដែន ខ្មែរ-យៀកណាម វាគ្រាន់ជាភ្លើងចំបើង ឆេះតែមួយភ្លែល ដូចសព្វដងតែប៉ុណ្ណោះ។

26/07/15